# ជំពូកទី ៦
# បញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

### *មាត្រា ៤២.- ថ្មី (មាត្រា ៤៨ ចាស់កែប្រែ)*

បញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៃឃុំ សង្កាត់នីមួយៗត្រូវយកបញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

### *មាត្រា ៤៣.- ថ្មី (មាត្រា ៤៩ ចាស់កែប្រែ)*

បញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវរៀបចំឱ្យបានយ៉ាងតិច៩០ (កៅសិប)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

**មាត្រា ៥០ ៥១ ៥២ ៥៣ ៥៤ ៥៥ ៥៦ ៥៧ ៥៨ ៥៩ ៦០ ៦១ ៦២ ៦៣ ៦៤ ៦៥ ៦៦ ៦៧ ៦៨ ៦៩ ៧០ ៧១ ៧២ ៧៣ ៧៤ ៧៥ ៧៦ ៧៧ ៧៨ ៧៩ ៨០ ៨១ ៨២ ៨៣ ៨៤ ៨៥ ៨៦ ៨៧ ៨៨ ៨៩ ៩០ ៩១ ៩២.-** ត្រូវបានលុបចោល ។

***មាត្រា ៤៤.- ថ្មី (មាត្រា ៩៣ ចាស់កែប្រែ)***

ក្នុងការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃការិយាល័យបោះឆ្នោតនីមួយៗ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ÷

- បញ្ចូលឈ្មោះអ្នកបោះឆ្នោតគ្រប់រូបក្នុងបញ្ជីនោះដោយដាក់អាសយដ្ឋាន អាយុ ភេទ
- បញ្ជាក់ឈ្មោះឃុំ សង្កាត់ និងលេខសម្គាល់ការិយាល័យបោះឆ្នោត
- រៀបចំបញ្ជីតាមទម្រង់ដូចគ្នា
- ចុះហត្ថលេខា និងកាលបរិច្ឆេទ ។

បញ្ជីឈ្មោះអ្នកបោះឆ្នោតអាចត្រូវធ្វើការកែសម្រួល និងដាក់បញ្ចូលគ្នាជាមួយបញ្ជីឈ្មោះអ្នកបោះឆ្នោតដទៃទៀត ដើម្បីបង្កើតបញ្ជីរួមមួយសម្រាប់បម្រើឱ្យការបោះឆ្នោតនានា ស្របតាមច្បាប់កំណត់ ។